

## ភិក្ខុ ងិន ភេន ឥន្ទបញ្ញោ

# ជីវប្រវត្តិ

ភិក្ខុ ងិន ភេន កើតថ្ងៃ អាទិត្យ ៨ តុលា ១៩២៨ ក្នុងឃុំ ភ្នំដិន ស្រុកគីរីវង់ ខេត្ត តាកែវ ។ ឪពុកឈ្មោះ វ័ន្ន ងិន ម្តាយឈ្មោះ ម៉ៅ ង៉ែត មុខរបរ ធ្វើស្រែ ។ បានរៀនចប់នៅ សាលាវត្ត ក្នុងឃុំរបស់ខ្លួន បានចូលរៀនធម្មវិន័យ និងសមាទានសីល ២ ឆ្នាំ រួចហើយ បានចូលបួស ... បានសិក្សា ប្រឡងជាប់សញ្ញាប័ត្រសាលាបាលី ជាន់ខ្ពស់ ក្រុងភ្នំពេញ ។ បានទទួលអាហាររូបករណ៍ ទៅបន្តការសិក្សា នៅមហា មកុដរាជវិទ្យាល័យ ប្រទេសថៃ អស់ពេល ៨ ឆ្នាំ ប្រឡងជាប់សញ្ញាប័ត្រ សាសនសាស្ត្របណ្ឌិត និទ្ទេសកិត្តិយស ។ ត្រឡប់មកកម្ពុជាវិញ បានទទួលតំណែង ព្រះរាជាគណៈថ្នាក់ពិសេស ព្រះមហា សាសនវង្សាធិបតី មេគណក្រុងភ្នំពេញ អគ្គាធិការរងនៃពុទ្ធិកសិក្សា សមាជិកគណៈ កម្មការ វេយ្យាករណ៍ខ្មែរ ក្រសួងអប់រំជាតិ ។ល។

សម័យ ប៉ុល ពត  គេបង្ខំឲ្យលាសិក្ខា  ទៅជាទាសករ  សម័យឃួនឈ្មានពាន បានចូលបួសវិញ គេឲ្យបុណ្យស័ក្តិខ្លះដែរ  ជាសមាជិកគណៈកម្មការសង្ឃ រដ្ឋធានី  គណៈកម្មការត្រួតពិនិត្យការបោះពុម្ពសៀវភៅធម៌ និងការសម្តែងធម៌ ។

នៅឆ្នាំ ១៩៩០ ដោយការឧបត្ថម្ភរបស់ ព្រះអង្គម្ចាស់ ស៊ី. ឥស្សរោ  ខ្ញុំអាត្មា បានឱកាសទៅព្យាបាលរោគនៅប្រទេសបារាំង ស្នាក់នៅវត្ត ពោធិវង្ស  ហើយក៏ស្នាក់នៅជាប់រៀងរហូតមកដល់សព្វថ្ងៃនេះ ។ ក្នុងពេលស្នាក់នៅនេះ  ខ្ញុំអាត្មា បានធ្វើកិច្ចការផ្សេងៗ តាមសមត្ថភាពរបស់ខ្លួន និងបានសរសេរកូនសៀវភៅធម៌តូចៗ  ចំនួនជាង សែសិបក្បាល ក្នុងនោះមានបទកំណាព្យខ្លះផង  ដូចបានចម្លងចងក្រងទុកមកនេះស្រាប់ ។

ខ្ញុំអាត្មា មិនមែនជាអ្នកចេះកំណាព្យទេ  គ្រាន់តែចូលចិត្ត បើលោកអ្នកឃើញមានខុសត្រង់កន្លែងណា សូមមេត្តាជួយកែតម្រូវផង ៕

សូមអរគុណ

ថ្ងៃ ៨  ខែតុលា  ឆ្នាំ ២០១៨

ភិក្ខុ ងិន ភេន  ឥន្ទបញ្ញោ